ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚៚៛៛

សាលាដំបូងខេត្តកំពង់ស្ពឺ

សំណុំរឿងរដ្ឋប្បវេណីលេខ: ៤៦
ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០២៣
សាលក្រមលេខ ៦៦ (ថ)
ចុះថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ ២០២៣

# សាលក្រម
## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ស្ពឺ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នា ថ្ងៃព្រហស្បតិ៍ ០៣រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ ដោយមានសមាសភាពដូចតទៅ ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ស្ពឺ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ

- **ដើមចោទ ៖**

- ឈ្មោះ [redacted] **យ៉ានឌី** ភេទស្រី អាយុ ៣២ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃនៅ [redacted] មានប្ដីឈ្មោះ [redacted] **និមល** មានកូនចំនួន ០១នាក់ ។

- **អ្នកតំណាងដោយអាណត្តិ ៖** លោក [redacted] អត្តលេខ [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ ។

- **ចុងចម្លើយ ៖**

-ឈ្មោះ [redacted] **និមល** ភេទប្រុស អាយុ ៣៤ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃនៅ [redacted] មានប្រពន្ធឈ្មោះ [redacted] **យ៉ានឌី** មានកូនចំនួន ០១នាក់ ។

### I. អង្គហេតុ និងចំណុចវិវាទ

**ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ ៖**

១. សុំលែងលះពីចុងចម្លើយឈ្មោះ [redacted] **និមល** ។

២. ការសុំសិទ្ធិអំណាចមេបាគ្រប់គ្រងកូនឈ្មោះ [redacted] **ត្រៃភូមិ** ភេទប្រុស អាយុ ០៩ឆ្នាំ ។

៣. សុំបែងចែកទ្រព្យសម្បត្តិរួមតាមច្បាប់ ។

៤. បង្គាប់ឲ្យចុងចម្លើយ និងឪពុកម្ដាយរបស់ចុងចម្លើយ រើ និងចាកចេញពីដីដែលជាទ្រព្យដោយឡែករបស់ដើមចោទ តាមការព្រមព្រៀង ដូចមានចែងក្នុងកិច្ចសន្យា ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២២ ។

៥. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីចុងចម្លើយ ។

**ខ. ការពន្យល់ត្រួសៗអំពីរឿងក្ដី ៖**

ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍នឹងគ្នា កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ មានសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍លេខ ០៣១ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ ។ ក្នុងចំណងអាពាហ៍ពិពាហ៍ដើមចោទ និងចុងចម្លើយមានកូនចំនួន ០១នាក់ ឈ្មោះ [redacted] **ត្រៃភូមិ** ភេទប្រុស អាយុ ០៩ឆ្នាំ ។ ចំពោះទ្រព្យសម្បត្តិរួមមានផ្ទះមួយខ្នងឈើលើថ្មក្រោម ទំហំ ៦ម៉ែត្រ គុណ



Scanned with CamScanner

នឹង ៨ ម៉ែត្រ ស្ថិតនៅភូមិស្រះស្រង់ ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដែលសាងសង់លើដីម្តាយរបស់ដើមចោទ ចំណែកឯបំណុលរួមពុំមានទេ ។ ដោយសារការរស់នៅមិនចុះសម្រុងគ្នា តែងតែមានរឿងរកាំរកុះ ឈ្លោះប្រកែកគ្នាជាញឹកញាប់ ជាពិសេសចុងចម្លើយជាមនុស្សប្រើប្រាស់គ្រឿងញៀនជាប្រចាំ ហេតុនេះទើបធ្វើឲ្យដើមចោទអស់មនោសញ្ចេតនាជាប្តីប្រពន្ធនឹងចុងចម្លើយតទៅទៀត ។

**គ. សេចក្តីថ្លែងការណ៍របស់គូភាគី ៖**

**-សេចក្តីថ្លែងការណ៍របស់ដើមចោទ:** នាងខ្ញុំ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍នឹងគ្នា កាលពីថ្ងៃទី ២២ ខែមេសា ឆ្នាំ២០១៣ តាមប្រពៃណីទំនៀមទម្លាប់ ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ មានសំបុត្រអាពាហ៍ពិពាហ៍លេខ ០៣១ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ ដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំសែនដី ។ ក្នុងអំឡុងពេលរស់នៅជាមួយគ្នា ខ្ញុំបាទ និងចុងចម្លើយមានកូនចំនួន ០១នាក់ឈ្មោះ [redacted] ត្រៃភូមិ ភេទប្រុស អាយុ ០៩ឆ្នាំ មានសំបុត្រកំណើតលេខ ០៤៣ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ ដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំសែនដី ចំពោះកូននេះនាងខ្ញុំសុំសិទ្ធិអំណាចមេបាគ្រប់គ្រងកូន ដោយហេតុថា ខ្ញុំមានភាពប៉ិនប្រសប់ក្នុងការមើលថែរក្សាកូន អាចផ្តល់ភាពកក់ក្តៅដល់កូនច្រើនជាងចុងចម្លើយ ខ្ញុំមានលទ្ធភាពអាចឲ្យកូនរៀនសាលាល្អបាន ផ្ទុយពីចុងចម្លើយដែលគ្មានមុខរបរច្បាស់លាស់ មិនអាចផ្តល់ភាពកក់ក្តៅដល់កូនបាន ។ ចំពោះអាហារកាតព្វកិច្ចចិញ្ចឹមកូននាងខ្ញុំមិនសុំទាមទារពីចុងចម្លើយទេ ។ ចំពោះទ្រព្យសម្បត្តិរួមមានដូចជា ផ្ទះមួយខ្នងឈើលើថ្មក្រោម ទំហំ ៦x៨ ស្ថិតនៅភូមិស្រះស្រង់ ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដែលសាងសង់លើដីរបស់ម្តាយនាងខ្ញុំ នាងខ្ញុំសុខចិត្តប្រគល់ឲ្យចុងចម្លើយគ្រប់គ្រងជាម្ចាស់កម្មសិទ្ធិ ប៉ុន្តែនាងខ្ញុំសុំឲ្យចុងចម្លើយរុះរើផ្ទះដែលសាងសង់លើដីរបស់ម្តាយបង្កើតនាងខ្ញុំនេះចេញ ។ បំណុលរួម រវាងខ្ញុំបាទ និងចុងចម្លើយមិនមានទេ ដូច្នេះខ្ញុំបាទមិនសុំឲ្យតុលាការធ្វើបែងចែកទេ ។ មូលហេតុដែលនាងខ្ញុំសុំលែងលះពីចុងចម្លើយ ដោយហេតុថា ការរស់នៅមិនចុះសម្រុងគ្នា ចេះតែមានរឿងរកាំរកុះកើតឡើង និងមានរឿងឈ្លោះប្រកែកគ្នាជាញឹកញាប់ ជាពិសេសចុងចម្លើយជាមនុស្សប្រើប្រាស់គ្រឿងញៀនជាប្រចាំ ទោះបីជាងនាងខ្ញុំបានហាមឃាត់យ៉ាងណាក៏គាត់មិនព្រមស្តាប់ ហើយបែរជាគម្រាមសម្លាប់នាងខ្ញុំថែមទៀតផង ហេតុនេះទើបធ្វើឲ្យនាងខ្ញុំអស់មនោសញ្ចេតនាជាប្តីប្រពន្ធនឹងចុងចម្លើយតទៅទៀត ។ អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកចៅក្រមសម្រេចតាមការទាមទារដោយក្តីអនុគ្រោះ ។

**-សេចក្តីថ្លែងការណ៍របស់ចុងចម្លើយ:** តុលាការបានធ្វើការបញ្ជូនដីកាកោះ ទៅចុងចម្លើយឈ្មោះ [redacted] និមល ត្រឹមត្រូវតាមនីតិវិធី ប៉ុន្តែចុងចម្លើយអវត្តមានដោយគ្មានមូលហេតុ ។

**ឃ.ចំណុចខុសគ្នា ៖ គ្មាន ។**

## II. ការពិនិត្យភស្តុតាង

**១. ភស្តុតាងជាឯកសាររបស់ដើមចោទ ៖**

**១.១.** សំបុត្រអាពាហ៍ពិពាហ៍លេខ ០៣១ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ ដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំសែនដី (ថតចម្លងចំនួន ០១ច្បាប់) ។

**១.២.** សំបុត្រកំណើតលេខ ០៤៣ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ ដែលចេញដោយមេឃុំសែនដី (ថតចម្លង ០១ច្បាប់) ។

## III.សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា ៖

**១.ស្តីពីការទាមទារទី១ ៖ ការសុំលែងលះពីចុងចម្លើយឈ្មោះ [redacted] និមល**



Scanned with CamScanner

**១.១-** តាមសំបុត្រអាពាហ៍ពិពាហ៍លេខ ០៣១ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំសែនដី ព្រមទាំងការអះអាងរបស់ដើមចោទថា ពួកខ្លួនបានរៀបការនឹងគ្នាទៅតាមប្រពៃណីនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដូចមាននៅក្នុងសំបុត្រអាពាហ៍ពិពាហ៍លេខ ០៣១ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំសែនដី គឺអាចឱ្យតុលាការទទួលស្គាល់ថាដើមចោទ និងចុងចម្លើយពិតជាបានរៀបការនឹងគ្នាតាមប្រពៃណីតាំងឆ្នាំ២០១៣ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ ពិតប្រាកដមែន ។ ការដែលដើមចោទ និងចុងចម្លើយរស់នៅជាមួយគ្នាដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍នឹងគ្នាបែបនេះ គឺមានន័យថាដើមចោទ និងចុងចម្លើយមានជាប់ចំណងអាពាហ៍ពិពាហ៍នឹងគ្នា គឺរស់នៅជាមួយគ្នាមានលក្ខណៈ ត្រឹមត្រូវតាមច្បាប់ ។

**១.២**-ដើមចោទបានអះអាងថា ខ្លួនសុំលែងលះជាមួយចុងចម្លើយដោយសារការរស់នៅមិនចុះសម្រុងនឹងគ្នា តែងតែមានរឿងរកាំរកុះ ឈ្លោះប្រកែកគ្នាជាញឹកញាប់ ។ តាមការអះអាងរបស់ដើមចោទនេះ ធ្វើឱ្យតុលាការទទួលស្គាល់ថា ចំណងអាពាហ៍ពិពាហ៍រវាងដើមចោទ និងចុងចម្លើយត្រូវបានបែកបាក់ ដោយគ្មានសង្ឃឹមថានឹងអាចធ្វើបដិទានឡើងវិញបាន ។

**១.៣-** ការដែលចំណងអាពាហ៍ពិពាហ៍រវាងដើមចោទ និងចុងចម្លើយត្រូវបានបែកបាក់ ដោយគ្មានសង្ឃឹមថានឹងអាចធ្វើបដិទានឡើងវិញបាន គឺបង្ហាញឱ្យឃើញថា ការទាមទារលែងលះរបស់ដើមចោទ គឺស្របតាមមាត្រា**៩៧៨-ង** នៃក្រមរដ្ឋប្បវេណី ដែលគប្បីតុលាការសម្រេចឱ្យដើមចោទ និងចុងចម្លើយលែងលះគ្នាតាមការស្នើសុំរបស់ដើមចោទ ។

**២.ស្តីពីការទាមទារទី២ ៖ ការសុំសិទ្ធិអំណាចមេបាគ្រប់គ្រងកូន**

**២.១**. តាមការអះអាងរបស់គូភាគី និងតាមសេចក្តីចម្លងសំបុត្រកំណើតលេខ ០៤៣ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ ដែលចេញដោយមេឃុំសែនដី បញ្ជាក់ឲ្យឃើញថា ដើមចោទ និងចុងចម្លើយ ពិតជាមានកូនចំនួន ០១នាក់ឈ្មោះ [redacted] **ត្រៃភូមិ** ភេទប្រុស កើតថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៤ មានសំបុត្រកំណើតលេខ ០៤៣ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ ដែលចេញដោយមេឃុំសែនដី ប្រាកដមែន ។

**២.២**. ដោយពិចារណាលើលក្ខណៈសម្បត្តិរបស់អ្នកមានអំណាចមេបា ឃើញថាដើមចោទមានមុខរបរច្បាស់លាស់ មានប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់សេដ្ឋកិច្ចគ្រួសារ និងផ្គត់ផ្គង់ការសិក្សាអប់រំរបស់កូន និងមានពេលវេលាគ្រប់គ្រាន់ក្នុងការមើលថែរក្សាកូន ផ្ទុយទៅវិញចុងចម្លើយគ្មានមុខរបរច្បាស់លាស់ ជាពិសេស ចុងចម្លើយជាមនុស្សដែលតែងតែប្រើប្រាស់គ្រឿងញៀនជាប្រចាំ ដែលជាគំរូអាក្រក់ដល់កូន ដូច្នេះ ចុងចម្លើយគ្មានពេលវេលាគ្រប់គ្រាន់ ដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូននោះទេ ។ ដោយពិចារណាលើចំណុចទាំងនេះ គប្បីតុលាការសម្រេចពិចារណាលើផលប្រយោជន៍ កុមារជាធំ ។

**២.៣-** សិទ្ធិអំណាចមេបាគ្រប់គ្រងកូនឈ្មោះ [redacted] **ត្រៃភូមិ** ភេទប្រុស កើតថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៤ ជាអនីតិជននៅឡើយ ដើម្បីជាប្រយោជន៍ដល់កូនដែលនៅវ័យក្មេង ត្រូវការភាពកក់ក្តៅ ចិញ្ចឹមបីបាច់ថែរក្សាអប់រំឲ្យបានល្អ ដោយហេតុថាភាគីដើមចោទត្រូវជាម្តាយមានភាពប៉ិនប្រសប់ក្នុងការចិញ្ចឹមកូនជាងឪពុក ចុង) ចម្លើយដែលគប្បីតុលាការប្រគល់សិទ្ធិអំណាចមេបាទៅ (ឲ្យភាគីដើមចោទគ្រប់គ្រង ចិញ្ចឹមបីបាច់ថែរក្សា អប់រំកូន ឈ្មោះ [redacted] **ត្រៃភូមិ** ភេទប្រុស កើតថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៤ រហូតដល់កូនពេញវ័យនីតិភាព ។

**៣. ស្តីពីការទាមទារទី៣ ៖ ការសុំបែងចែកទ្រព្យសម្បត្តិរួម**

- ចំពោះទ្រព្យសម្បត្តិរួម ដើមចោទបានអះអាងថា មានផ្ទះមួយខ្នងឈើលើថ្មក្រោម ទំហំ ៦ម៉ែត្រ គុណនឹង ៨ម៉ែត្រ ស្ថិតនៅភូមិស្រះស្រង់ ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដែលសាងសង់លើដី ដែលជាទ្រព្យសម្បត្តិដោយឡែករបស់ម្តាយខ្លួន ចំពោះទ្រព្យសម្បត្តិរួមនេះដើមចោទសុខចិត្តប្រគល់ឲ្យចុងចម្លើយគ្រប់គ្រងជាម្ចាស់កម្មសិទ្ធិ ហេតុនេះគប្បីតុលាការសម្រេចតាមការទាមទាររបស់ដើមចោទ ។



Scanned with CamScanner

**៤. ស្តីពីការទាមទារទី៤ ៖** បង្គាប់ឲ្យចុងចម្លើយ និងឪពុកម្តាយរបស់ចុងចម្លើយ រើ និងចាកចេញពីដីដែលជាទ្រព្យដោយឡែករបស់ដើមចោទ តាមការព្រមព្រៀង ដូចមានចែកក្នុងកិច្ចសន្យា ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ ២០២២ ។

៤.១. ភាគីដើមចោទបានអះអាងថា ក្នុងអំឡុងពេលរស់នៅជាមួយគ្នាជាមួយចុងចម្លើយ ខ្លួន និងចុងចម្លើយបានសាងសង់ផ្ទះទំហំ ៦ម៉ែត្រ គុណនឹង ៨ម៉ែត្រ នៅលើដីដែលកម្មសិទ្ធិរបស់ម្តាយបង្កើតខ្លួន រហូតដល់បច្ចុប្បន្ន ប៉ុន្តែដោយសាររស់នៅមិនចុះសម្រុងនឹងគ្នា ខ្លួនក៏សម្រេចចិត្តរស់នៅបែកលំនៅដ្ឋានពីចុងចម្លើយ និងដាក់ពាក្យបណ្តឹងលែងលះមកតុលាការ ដោយសុខចិត្តប្រគល់ផ្ទះដែលជាទ្រព្យសម្បត្តិរួមឲ្យទៅចុងចម្លើយ ប៉ុន្តែចុងចម្លើយត្រូវរើផ្ទះចេញពីដីម្តាយបង្កើតរបស់ខ្លួន ។

៤.២. តាមកិច្ចសន្យារវាងដើមចោទ និងចុងចម្លើយ ឃើញថាភាគីចុងចម្លើយយល់ព្រមរើផ្ទះចេញពីដីរបស់ម្តាយបង្កើតដើមចោទនៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៣ ប្រសិនបើដល់ថ្ងៃកំណត់រុះរើផ្ទះហើយ ចុងចម្លើយមិនព្រមរុះរើទេនោះ ដើមចោទមានសិទ្ធិក្នុងការរុះរើផ្ទះចេញពីដីម្តាយបង្កើតរបស់ខ្លួនដោយគ្មានល័ក្ខខ័ណ្ឌអ្វីទាំងអស់ ដូច្នេះគប្បីតុលាការសម្រេចតាមការទាមទាររបស់ដើមចោទ ។

៥. តុលាការបានធ្វើការបញ្ជូនដីកាកោះឲ្យចុងចម្លើយត្រឹមត្រូវតាមនីតិវិធីរួចហើយ ប៉ុន្តែចុងចម្លើយមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវចាត់ទុកថាចុងចម្លើយបានសារភាពតាមសេចក្តីថ្លែងការណ៍របស់ ដើមចោទដែលទាក់ទងនឹងអង្គហេតុ ។ ដូច្នេះគប្បីតុលាការសម្រេចតាមការទាមទាររបស់ដើមចោទស្រប តាមមាត្រា ២០១ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**៦. ប្រាក់ប្រដាប់ក្តី ៖** ប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## IV.សេចក្តីសម្រេចបញ្ចប់

១. ឲ្យដើមចោទឈ្មោះ [redacted] **យ៉ានទី** លែងលះចុងចម្លើយឈ្មោះ [redacted] **និមល** ។

២. កំណត់យកម្តាយឈ្មោះ [redacted] **យ៉ានទី** ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] **ត្រៃភូមិ** ភេទប្រុស កើតថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៤ មានសំបុត្រកំណើតលេខ ០៤៣ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ ដែលចេញដោយមេឃុំសែនដី ។

ភាគីដែលពុំមានអំណាចមេបា មានសិទ្ធចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន ហើយភាគីដែលមានអំណាចមេបា ត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀត ។

៣. ឲ្យចុងចម្លើយមានសិទ្ធិគ្រប់គ្រងផ្ទះឈើលើថ្មក្រោម ទំហំ ៦ម៉ែត្រ គុណនឹង ៨ម៉ែត្រ ស្ថិតនៅភូមិស្រះស្រង់ ឃុំសែនដី ស្រុកសំពោងទង ខេត្តកំពង់ស្ពឺ ។

៤. បង្គាប់ឲ្យចុងចម្លើយ រុះរើផ្ទះ និងចាកចេញពីដីដែលជាទ្រព្យដោយឡែករបស់ម្តាយបង្កើតដើមចោទ ។

៥. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចុងចម្លើយ ។

សាលក្រមនេះប្រកាសជាសាធារណៈនៅថ្ងៃអង្គារ ១០កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧ ត្រូវនឹងថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ នៅចំពោះមុខដើមចោទ និងចុងចម្លើយ និងបើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ចៅក្រម**

ហត្ថលេខា និងត្រា ៖ [redacted]

---

អនុសារសាលក្រមនេះមានអានុភាពដូចមូលសាលក្រមដែរ

ថ្ងៃអង្គារ ១០កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

កំពង់ស្ពឺ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣

**បានឃើញ**

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner